ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ព្រឹទ្ធសភា

# របាយការណ៍
# ស្តីពី
# លទ្ធផលការងាររបស់ព្រឹទ្ធសភា
# ប្រចាំខែកុម្ភៈ ឆ្នាំ២០១៩

*នៅក្នុងខែកុម្ភៈ ឆ្នាំ២០១៩នេះ ព្រឹទ្ធសភាបានបំពេញភារកិច្ចដូចតទៅ:*

## ១-សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភា

### ១.១-សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា បាន៖

*-អញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីបុណ្យវប្បធម៌ ដើម្បីរំលឹកអនុស្សាវរីយ៍លើកទី៦០នៃទំនាក់ទំនងការទូតរវាងឥណ្ឌូនេស៊ី និងកម្ពុជា ក្រោមអធិបតីភាពនៃ**ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា នៅសាលសន្និសីទចតុមុខ*

*-អញ្ជើញជាអធិបតីក្នុងពិធីបុណ្យបញ្ចុះខ័ណ្ឌសីមាព្រះវិហារពុទ្ធាភិសេក និងសម្ពោធសមិទ្ធផលនានា ក្នុងវត្តភ្នំធម្មតាអរ ស្ថិតនៅឃុំធម្មតាអរ ស្រុកសំពៅងទង ខេត្តកំពង់ស្ពឺ*

*-អញ្ជើញចូលរួមជាកិត្តិយសក្នុងព្រះរាជពិធីលៀងសាយភោជន៍ នៅព្រះរាជដំណាក់សិរីមង្គល ក្នុងព្រះបរមរាជវាំង*

*-អញ្ជើញពិសារអាហារថ្ងៃត្រង់ និងជួបប្រាស្រ័យជាមួយប្រជាពលរដ្ឋប្រមាណជាង ៣៥០នាក់ ដែលអញ្ជើញមកពីភូមិទាំង១៤ ក្នុងឃុំកោះសូទិន ក្នុងឱកាសដែលសម្តេច និងលោកជំទាវ ព្រមទាំងក្រុមគ្រួសារប្រារព្ធពិធីបុណ្យ១០០ថ្ងៃឧទ្ទិសកុសលជូនដល់ដួងវិញ្ញាណក្ខន្ធឧបាសក **សាយ គឹមស៊ាន** ដែលត្រូវជាបងបង្កើតរបស់សម្តេច*

*-អញ្ជើញជួបសំណេះសំណាល និងសាកសួរសុខទុក្ខប្រជាពលរដ្ឋ នៅតាមខ្នងផ្ទះក្នុងភូមិចំនួន០៥ នៃឃុំកោះសូទិន ដែលជាទឹកដីកំណើតរបស់សម្តេចផ្ទាល់ ស្ថិតនៅស្រុកកោះសូទិន ខេត្តកំពង់ចាម និងប្រជាពលរដ្ឋជាសាសនិកឥស្លាមប្រមាណជាង ៣០០នាក់ នៅវិហារភូឡាលោម ក្នុងភូមិ២ សង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ*

*-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន២៨ច្បាប់ និងជ្រាបជាព័ត៌មានចំនួន១៨ច្បាប់ ។*

វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443 ទូរសារ: (855 23) 211 446, E-mail: oum_sarith@camnet.com.kh

**១.២-ឯកឧត្តម ស៊ឹម កា អនុប្រធានទី១ព្រឹទ្ធសភា បាន** :

-អញ្ជើញចូលរួមប្រជុំពិភាក្សាការងារ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់នៃ**សម្តេចវិបុលសេនាភក្តី សាយ ឈុំ** ប្រធានព្រឹទ្ធសភា

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗ និងជ្រាបជាព័ត៌មានចំនួន២៤ច្បាប់ ។

**១.៣-ឯកឧត្តម ទេព ងន អនុប្រធានទី២ ព្រឹទ្ធសភា បាន** :

-អនុញ្ញាតឱ្យលោក NHUYEN TRAC TOAN លេខាទូតទី១នៃស្ថានទូតវៀតណាមប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ចូលជួបសម្តែងការគួរសម

-អញ្ជើញចូលរួមប្រជុំពិភាក្សាការងារដកបទពិសោធន៍នៃការរៀបចំបុណ្យខួបលើកទី៤០ នៃទិវាជ័យជម្នះ៧មករា

-អញ្ជើញចូលរួមពិធីបុណ្យខួបគម្រប់១០០ថ្ងៃ ឧទ្ទិសកុសលជូនចំពោះដួងវិញ្ញាណក្ខន្ធឧបាសក **សាយ គឹមស៊ាន** នៅឃុំកោះសូទិន ខេត្តកំពង់ចាម

-អញ្ជើញប្រារព្ធខួបគម្រប់៩ឆ្នាំ ឧទ្ទិសកុសលជូនចំពោះដួងវិញ្ញាណក្ខន្ធលោកជំទាវ **ភូ ធៀន** នៅវត្តប្រាំបីមុំ ស្រុកទ្រាំង ខេត្តតាកែវ

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន៤៦ច្បាប់ និងជ្រាបជាព័ត៌មានចំនួន១០ច្បាប់ ។

**២-គណៈកម្មការជំនាញនានារបស់ព្រឹទ្ធសភា** :

ក្នុងខែកុម្ភៈនេះ សមាជិក សមាជិកាព្រឹទ្ធសភា បានបំពេញការងារយ៉ាងសកម្មតាមតួនាទី ភារកិច្ច និងសមត្ថកិច្ចរបស់ខ្លួនប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ដូចខាងក្រោម:

**២.១- មុខងារតាមដានការអនុវត្តច្បាប់ និងគោលនយោបាយនានា**

-អញ្ជើញចូលរួមសន្និសីទការងារជាមួយក្រសួងព័ត៌មាន នៅទីស្តីការក្រសួងព័ត៌មាន

-អញ្ជើញចុះបំពេញបេសកកម្ម ដើម្បីឈ្វេងយល់អំពីវឌ្ឍនភាពនៃការអនុវត្តច្បាប់ស្តីពី ការប្រឆាំងអំពើពុករលួយ ការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ និងការអភិវឌ្ឍមូលដ្ឋាន នៅខេត្តរតនគិរី និងខេត្តមណ្ឌលគិរី

-អញ្ជើញចុះបំពេញបេសកកម្ម ដើម្បីឈ្វេងយល់ពីសភាពការណ៍ពាក់ព័ន្ធនឹងវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការ នៅខេត្តតាកែវ ខេត្តកែប ខេត្តកំពត ខេត្តស្ទឹងត្រែង ខេត្តរតនគិរី និងខេត្តមណ្ឌលគិរី ។

**២.២- មុខងារតំណាង**

-បានទទួលពាក្យបណ្តឹងចំនួន០៣ករណី និងធ្វើកំណត់បង្ហាញពាក្យបណ្តឹងចំនួន០៤ករណី បញ្ជូនទៅស្ថាប័នមានសមត្ថកិច្ចពិនិត្យដោះស្រាយចំនួន០៤ករណី ទទួលលិខិតឆ្លើយតបការដោះស្រាយពាក្យបណ្តឹងពីក្រសួង ស្ថាប័នពាក់ព័ន្ធចំនួន០៣ករណី

និងផ្តល់ព័ត៌មានទៅម្ចាស់បណ្តឹងវិញអំពីលទ្ធផលទទួលបានពីការឆ្លើយតបរបស់ក្រសួង ស្ថាប័នចំនួន០៣ករណី និងទទួលឯកសារពាក្យបណ្តឹងពីក្រសួង ស្ថាប័ន ដែលចម្លងជូនមកព្រឹទ្ធសភាជ្រាបចំនួន០៥ករណី

-ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៤ បានរៀបចំសិក្ខាសាលាស្តីពី នីតិវិធីទប់ស្កាត់គ្រោះថ្នាក់អគ្គិភ័យ និងផ្សព្វផ្សាយលិខិតបទដ្ឋានស្តីពី ការបង្ការពន្លត់ អគ្គិភ័យ និងសង្គ្រោះ

-អញ្ជើញចូលរួមកិច្ចប្រជុំកំពូលស្តីពី សន្តិភាពនៃគណៈកម្មាធិការនារីអន្តរជាតិ

-អញ្ជើញចូលរួមសន្និសីទស្តីពី សន្តិភាពពិភពលោក ក្រោមប្រធានបទ ភាពសុខដុម ការប្រាស្រ័យទាក់ទង និងសន្តិភាពជាមួយនឹងស្ត្រីចំនួន៣៧០០លាននាក់ នៅលើពិភពលោក

-អញ្ជើញចូលរួមប្រជុំពិនិត្យ និងផ្តល់យោបល់លើរបាយការណ៍វេទិកានៅខេត្តកំពង់ធំ និងផែនការប្រតិបត្តិឆ្នាំ២០១៩

-អញ្ជើញចូលរួមប្រជុំបូកសរុបរបាយការណ៍សកម្មភាពការងារ របាយការណ៍ថវិកាប្រចាំឆ្នាំ២០១៨ និងទិសដៅការងារបន្ត ជាមួយក្រុមមិត្តភាពព្រឹទ្ធសភាកម្ពុជា-ឡាវ-វៀតណាម

-អញ្ជើញចូលរួមកិច្ចប្រជុំស្តីពី ការរៀបចំធ្វើបច្ចុប្បន្នភាពរចនាសម្ព័ន្ធរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អញ្ជើញចូលរួមកិច្ចប្រជុំបូកសរុបលទ្ធផលការងារឆ្នាំ២០១៨ និងលើកទិសដៅការងារឆ្នាំ២០១៩ របស់ក្រុមប្រឹក្សាជាតិដើម្បីស្ត្រី

សមាជិក សមាជិកាព្រឹទ្ធសភា បានអញ្ជើញចុះទៅតាមបណ្តាខេត្ត ក្រុង និងរាជធានីភ្នំពេញចំនួន១០៦លើក ដើម្បីជួបពិភាក្សាការងារ សំណេះសំណាល សាកសួរសុខទុក្ខប្រជាពលរដ្ឋ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តចុះពិនិត្យ និងព្យាបាលជំងឺជូនប្រជាពលរដ្ឋ ពិនិត្យការដ្ឋានសាងសង់ សម្ពោធសមិទ្ធផលនានា តាមដានការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រោមជាតិ ការអនុវត្តគោលនយោបាយភូមិ ឃុំមានសុវត្ថិភាព សិក្សាឈ្វេងយល់អំពីស្ថានភាពសិទ្ធិមនុស្ស ការអនុវត្តច្បាប់ កែលម្អសេវាសាធារណៈ ពង្រឹងអភិបាលកិច្ចល្អនៅមូលដ្ឋាន និងគោលនយោបាយផ្សេងៗលើគ្រប់វិស័យ ព្រមទាំងបានចូលរួមក្នុងពិធីផ្លូវការ និងពិធីផ្សេងៗ សរុបចំនួន៥៣លើក ។

**៣- កិច្ចសហប្រតិបត្តិការអន្តរជាតិ :**

-លោកជំទាវ **មាន សំអាន** និងលោកជំទាវ **មុំ សណ្តាប់** អមដំណើរដោយគណៈប្រតិភូជាន់ខ្ពស់សមាគមនារីកម្ពុជាដើម្បីសន្តិភាព និងអភិវឌ្ឍន៍ អញ្ជើញទៅបំពេញទស្សនកិច្ច ជាផ្លូវការ នៅសាធារណរដ្ឋសង្គមនិយមវៀតណាម

-ឯកឧត្តម **ចាន់ ណាវ៉េត** អញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ទទួលបន្ទុកកិច្ចការសង្គម និងវប្បធម៌របស់សភាតំបន់អាស៊ី(APA) នៅទីក្រុងបាងកក នៃព្រះរាជាណាចក្រថៃឡង់ដ៍

-ឯកឧត្តម **ខៀវ មុត** អញ្ជើញចូលរួមសន្និសីទអន្តរជាតិលើកទី២ស្តីពី ការវាយតម្លៃ APEA Conference 2019 នៅទីក្រុងម៉ានីល នៃប្រទេសហ្វីលីពីន

-ឯកឧត្តម **ឡាន់ ឆន** អញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីអបអរសាទបុណ្យចូលឆ្នាំថ្មីប្រពៃណីជនជាតិវៀតណាមជាមួយថ្នាក់ដឹកនាំខេត្តតៃនិញ នៅខេត្តតៃនិញ នៃសាធារណរដ្ឋសង្គមនិយមវៀតណាម

-ឯកឧត្តម **គង់ សារាជ** និងឯកឧត្តម **ម៉ែន ស៊ីផាន់** អញ្ជើញចូលរួមជំនួបសម្តែងការគួរសម និងពិភាក្សាការងារជាមួយឯកឧត្តម Francois Grosdidier អនុប្រធានក្រុមមិត្តភាពបារាំង កម្ពុជា

-ឯកឧត្តម **ម៉ុង ឫទ្ធី** អញ្ជើញជួបពិភាក្សាការងារជាមួយលោកប្រធានទំនាក់ទំនងភ្ញៀវអន្តរជាតិរបស់ក្រុមហ៊ុន China Road and Bridge Corporation (Cambodia) ស្តីពីការសិក្សាសាងសង់ផ្លូវល្បឿនលឿនពីភ្នំពេញ ទៅខេត្តព្រះសីហនុ។

ថ្ងៃ[illegible] ខែ[illegible] ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែមីនា ឆ្នាំ២០១៩

**ជ.ប្រធានព្រឹទ្ធសភា**

**អនុប្រធានទី២**

**ទេព ងន**

ចម្លងជូន:
- ក្រសួងព្រះបរមរាជវាំង
- ក្រុមប្រឹក្សាធម្មនុញ្ញ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងយុត្តិធម៌
- ក្រសួងព័ត៌មាន
- (ទូលថ្វាយ និងជូនជ្រាបជាព័ត៌មាន)
- កាលប្បវត្តិ-ឯកសារ